ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៦៧៧......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
## សម្រាប់ឆ្នាំ២០១៣

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់យានយន្ត និងយានជំនិះគ្រប់ប្រភេទ មេត្តាជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ត្រូវបានអនុវត្តតាមប្រកាសលេខ១៤៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ និងសេចក្តីជូនដំណឹងលេខ០០៥ សហវ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ។

ក្នុងអំឡុងពេលប្រមូលពន្ធ ទោះបីជាអគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតពន្យារពេលរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ក៏ដោយ ក៏មានម្ចាស់យានយន្តមួយចំនួននៅតែពុំទាន់មកប្រកាសបង់ពន្ធនេះនៅឡើយ ។ ដើម្បីចៀសវាងនូវការថ្នាំងថ្នាក់ក្នុងការត្រួតពិនិត្យ និងការចាប់បង្ខំឱ្យបង់ពន្ធនៅនឹងកន្លែងត្រួតពិនិត្យ ម្ចាស់យានយន្ត និងយានជំនិះគ្រប់ប្រភេទដែលមិនទាន់បានប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន សូមអញ្ជើញទៅប្រកាសបង់ពន្ធសម្រាប់ឆ្នាំ២០១៣នៅការិយាល័យប្រមូលពន្ធនៃសាខាពន្ធដារខេត្ត-ខណ្ឌ ឱ្យបានមុនពេលដែលអគ្គនាយកដ្ឋានពន្ធដារចាត់មន្ត្រីចុះត្រួតពិនិត្យក្នុងពេលឆាប់ៗខាងមុខនេះ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា អស់លោក លោកស្រីទាំងអស់ ជាម្ចាស់យានយន្ត និងយានជំនិះគ្រប់ប្រភេទ ដែលខកខានមិនបានមកប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពិតជានឹងយកចិត្តទុកដាក់ និងអញ្ជើញមកបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានទាន់ពេលវេលា មុនការចុះត្រួតពិនិត្យដោយមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

**ចម្លងជូន ÷**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីកសហវ
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- សាខាពន្ធដារខេត្ត- ខណ្ឌ
  "ដើម្បីមុខការ"

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh